


# ដីនៅស្រុកអូររាំងឪខេត្តកំពង់ចាមនៃប្រទេសកម្ពុជា

☆☆☆ឯកសារនេះពិពណ៌នាអំពីក្រុមដីផ្សេងៗ ដែលមាននៅក្នុងស្រុកអូររាំងឪ នៃខេត្តកំពង់ចាម ដែលជាព័ត៌មានគ្រឹះអំពីដី សំរាប់ធ្វើការស្វែងយល់ និង សិក្សាស្រាវជ្រាវ

| ឯកត្តាផែនទី | ការពិពណ៌នាសង្ខេប | ឯកត្តាផែនទី | ការពិពណ៌នាសង្ខេប |
|---|---|---|---|
| KC1 | តំបន់ខ្ពង់រាបបាសាល់ ដែលមានសណ្ឋានដីខ្ពស់ទាប ខ្សោយទៅខ្លាំង, ដីមានមានលក្ខណៈជាដីឥដ្ឋពណ៌ក្រហម (ក្រុមដីឡាបានសៀកគ្មានក្រួស)។ ជាតំបន់ដាំដុះដំណាំកៅស៊ូ ឬ ដំណាំចំការ។ | KC2 | តំបន់ដែលមានសណ្ឋានដីជាជំរាលខ្សោយទៅមធ្យមស្ថិតនៅជាយនៃតំបន់ខ្ពង់រាបបាសាល់ និង ទីទួលបាសាល់ទាបៗ ហើយដីមានដុំថ្មតូចៗ ឬក្រួស ដែលដីមានពណ៌ត្នោត (ក្រុមដីអូររាំងឪ)។ ជាតំបន់ដាំដុះ ដំណាំចំការ។ |
| KC3 | តំបន់ដែលមានសណ្ឋានដីជាជំរាលខ្សោយស្ថិតនៅជុំវិញតំបន់ខ្ពង់រាបបាសាល់។ ដីមានលក្ខណៈជាដីឥដ្ឋពណ៌ក្រហម ឬក្រមៅ មានវត្តមានថ្មរបាសាល់នៅស្រទាប់ក្រោម (ក្រុមដីកំពង់សៀមមានក្រួស និងគ្មានក្រួស)។ ជាតំបន់ដាំដុះដំណាំស្រូវ និងដំណាំចំការ។ | KC4 | តំបន់វាលរាប ស្ថិតនៅជុំវិញតំបន់ខ្ពង់រាបបាសាល់ ជាញឹកញយគេឃើញស្ថិតនៅជំរាលផ្នែកខាងក្រោមនៃតំបន់ KC3។ ដីមានលក្ខណៈជាដីឥដ្ឋពណ៌ក្រម៉ៅ មានវត្តមានថ្មរបាសាល់នៅស្រទាប់ក្រោម (ក្រុមដីកំពង់សៀម គ្មានក្រួស)។ ជាតំបន់ដាំដុះដំណាំស្រូវ។ |
| KC5 | តំបន់វាលរាបល្បាប់លិចទឹក ២-៤ ខែ ក្នុងមួយឆ្នាំ។ ដីមានលក្ខណៈជាដីឥដ្ឋ ពណ៌ក្រមៅ (ក្រុមដីកំពង់សៀមគ្មានក្រួស)។ ជាតំបន់ដាំដុះដំណាំស្រូវ។ | KC6 | តំបន់លិចទឹក ដែលមានសារពើរុក្ខជាតិ។ |
| KC7 | ជាតំបន់លិចទឹកលិចទឹកអចិន្ត្រៃយ៍ (បឹង ឬត្រពាំង)។ | KC8 | តំបន់វាលរាបល្បាប់លិចទឹក ២-៤ ខែ ក្នុងមួយឆ្នាំ។ ដីមានលក្ខណៈជាខ្សាច់ទៅឥដ្ឋពណ៌លឿងទៅត្នោត (ក្រុមដីប្រទះឡាង, បាកាន)។ ជាតំបន់ដាំដុះដំណាំស្រូវ។ |
| KC9 | តំបន់ទឹកចេញពីតំបន់ខ្ពង់រាបបាសាល់។ មានកាលានុវត្តភាពក្នុងការស្រោចស្រព និងការដាំដុះដំណាំ។ ជាតំបន់ដាំដុះដំណាំហូបផ្លែ និងព្រៃរបោះធម្មជាតិ។ | KC10 | តំបន់ទំនាប និងភាគច្រើនស្ថិតតាមបណ្តោយចេញពីតំបន់ខ្ពង់រាប បាសាល់។ ជាតំបន់ដាំដុះដំណាំស្រូវ និងដំណាំចំការ។ |



# KC1

## ក្រុមដី: ឡាបានសៀក អនុក្រុមគ្មានក្រួស

**World Reference Base: Eutric Nitosol**

**ភូមិ: ដំណាក់កែវ   ឃុំ: ទួលសូភី**

- 0 - 15 cm ស្រទាប់ A, ជាដីឥដ្ឋ ពេលសើមពណ៌ត្នោតក្រហមក្រមៅ (2.5YR3/3), មានរចនាសម្ព័ន្ធដីខ្សោយ និងមានភាពរឹង, pH($CaCl_2$) 4.4, មានដុំតូចៗនៃរ៉ែដែកតិចតួច, មានវត្ថុមាននៃឫសរុក្ខជាតិច្រើនបង្គួរ,
- 15 - 60 cm ស្រទាប់ B ជាដីឥដ្ឋ ពេលសើមពណ៌ត្នោតក្រហមចាស់ (2.5YR3/4), មានរចនាសម្ព័ន្ធដីមធ្យម និងមានភាពផុយ, pH($CaCl_2$) 4.5, មានវត្ថុមាននៃឫសរុក្ខជាតិតិចតួច,
- 60 to 120+ cm ស្រទាប់ B ជាដីឥដ្ឋ ពេលសើមពណ៌ក្រហមក្រម៉ៅ (2.5YR3/6), មានវត្ថុមានស្នាមចំរុះតូចៗក្រហមភ្លឺ (2.5YR6/8) ចំនួនច្រើនបង្គួរ, រចនាសម្ព័ន្ធមធ្យមនិងមានភាពផុយ, pH(CaCl2) 4.4, មានវត្ថុមាននៃឫសរុក្ខជាតិតិចតួច ។












# KC2

## ក្រុមដី: អូរាំងឪ

**World Reference Base: Ferric Lixisol**

**ភូមិ: ស្ទឹង   ឃុំ: ទួលសូភី**

- 0-12 cm ស្រទាប់ A, ជាដីល្បាយឥដ្ឋ ពេលសើមពណ៌ត្នោតប្រផេះក្រមៅខ្លាំង (10YR3/2), រចនាសម្ព័ន្ធដីជាដុំផ្ទាំងធំៗ និងមានភាពរឹងល្មម, pH($CaCl_2$) 5.7, មានដុំតូចៗនៃរ៉ែដែកជាច្រើន, មានវត្ថុមាននៃឫសរុក្ខជាតិច្រើនបង្គួរ;
- 12-85 cm ស្រទាប់ BC, ជាដីឥដ្ឋបាសាល់ ពេលសើមពណ៌ត្នោតក្រមៅ (10YR3/3), មានរចនាសម្ព័ន្ធដីមធ្យម,មានភាពផុយ, ដុំតូចៗនៃរ៉ែដែកជាច្រើន, pH($CaCl_2$) 5.5, មានវត្ថុមាននៃឫសរុក្ខជាតិតិចតួច, មានបំណែកក្រួសគ្រើម តិចតួច ;
- 85-120+cm ស្រទាប់ BC, ជាដីឥដ្ឋ ពេលសើមត្នោត (10YR4/3), មានរចនាសម្ព័ន្ធដីខ្សោយ,មានភាពផុយ, មានដុំតូចៗល្មមនៃរ៉ែដែកច្រើន, pH($CaCl_2$) 5.4, គ្មានវត្ថុមាននៃឫស, ស្នាមចំរុះតូចៗពណ៌ត្នោតភ្លឺ (7.5YR6/4) ចំនួនតិចតួច ។

# KC3

## ក្រុមដី: កំពង់សៀម

**World Reference Base: Gleyic Phaeozem**

**ភូមិ: ទួលថ្កូវ   ឃុំ: ព្រះធាតុ**



- 0-10 cm ស្រទាប់ A, ជាដីឥដ្ឋ ពេលសើមពណ៌ប្រផេះក្រម៉ៅខ្លាំង (10YR3/1),រចនាសម្ព័ន្ធដីខ្សោយ និងមានភាពរឹងខ្លាំងពេលស្ងួត, មានដុំតូចៗនៃរ៉ែដែកតិចតួច, pH($CaCl_2$) 5.6, មានវត្ថុមាននៃឫសរុក្ខជាតិច្រើនបង្គួរ, ស្នាមចំរុះតូចៗពណ៌ត្នោត (7.5YR4/4) តិចតួច;
- 10-40 cm ស្រទាប់ A, ជាដីឥដ្ឋ ពេលសើមពណ៌ត្នោតប្រផេះក្រម៉ៅខ្លាំង (10YR3/2), រចនាសម្ព័ន្ធដីខ្សោយ និងមានភាពផុយ, មានដុំតូចៗនៃរ៉ែដែកតិចតួច, pH($CaCl_2$) 6.1,វត្ថុមាននៃឫសរុក្ខជាតិតិចតួច, មានស្នាមចំរុះតូចៗពណ៌ត្នោត (7.5YR4/4) តិចតួច;
- 40-75 cm ស្រទាប់ BC, ជាដីឥដ្ឋ ពេលសើមពណ៌ត្នោតប្រផេះក្រម៉ៅ (10YR4/2), រចនាសម្ព័ន្ធដីមធ្យមនិងមានភាពផុយ, ជាទូទៅមានដុំតូចៗនៃរ៉ែដែកជាច្រើននិងមានវិយោគកម្មម៉ង់កាណែស, pH($CaCl_2$) 6.3, គ្មានវត្ថុមានឫសរុក្ខជាតិ, មានស្នាមចំរុះតូចៗពណ៌ត្នោតខ្លាំង (7.5YR4/6) តិចតួច;
- 75-115+ cm ស្រទាប់ C, ជាដីឥដ្ឋ ពេលសើមពណ៌ប្រផេះក្រហម (2.5YR5/1), រចនាសម្ព័ន្ធដីខ្សោយនិងមានភាពរឹងខ្លាំង, ជាទូទៅមានដុំតូចៗនៃរ៉ែដែក និងវិយោគកម្មម៉ង់កាណែស, pH($CaCl_2$) 5.9, គ្មានវត្ថុមាននៃឫសរុក្ខជាតិ, មានស្នាមចំរុះតូចៗពណ៌ត្នោតចាស់ (7.5YR4/6) ច្រើនបង្គួរ ។


សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង កម្មវិធីវិទ្យាសាស្ត្រដី និងទឹក ឬមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ឬការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជា ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ,ទូរសព្ទ័លេខ:( ៨៥៥-២៣ )២១៩ ៦៩៣-៤

ទូរសារលេខ: ( ៨៥៥-២៣ ) ២១៩ ៨០០,   ទូរអក្ខរ: cardi@cardi.org.kh   វែបសាយ: www.cardi.org.kh

VSeng@cardi.org.kh   TRIN@cardi.org.kh   HUNYADANA@cardi.org.kh